សាលាដំបូងខេត្តសៀមរាប

-សំណុំរឿងព្រហ្មទណ្ឌលេខ ៨៣៩
ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ ៣៣១
ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០
-សំណុំរឿងជំនុំជម្រះលេខ ៨៣៧
ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌលេខ ១១៦ (ខ)
ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង០៨ និង ៣០នាទីព្រឹក នៅសាលសវនាការលេខ ០១B ដែលមានសមាសភាព ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រីចៅក្រម [redacted] ប្រធានក្រុមប្រឹក្សា
លោកចៅក្រម [redacted] ចៅក្រមប្រឹក្សា
លោកចៅក្រម [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី សាលាដំបូង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៣៩ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] ចាន់វណ្ណៈពេជ្រ ភេទប្រុស អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

-លោក [redacted] ជាមេធាវីការពារសិទ្ធិ

-លោក [redacted] ជាមេធាវីការពារសិទ្ធិ

-ជាប់ចោទពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ [redacted] **ដា** ភេទស្រី អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរទីលំនៅបច្ចុប្បន្នភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ។

-អ្នកដាក់ពាក្យបណ្តឹងឈ្មោះ [redacted] **ខេម** ភេទស្រី អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

# អង្គហេតុកើតមានឡើងដូចតទៅ

កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១០និង៣០នាទី ឈ្មោះ [redacted] ងា ភេទស្រី អាយុ១៧ឆ្នាំ កំពុងតែអង្គុយលេងមុខបន្ទប់ជួលរបស់នាង ស្ថិតនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ស្រាប់តែឃើញឈ្មោះ [redacted] ចាន់វណ្ណៈពេជ្រ ដែលជាមិត្តប្រុសរបស់មិត្តភ័ក្តនាង រស់នៅផ្ទះជួលជិតគ្នា ដោយនាងឃើញជនជាប់ចោទ គ្មានសោរចូលបន្ទប់ នាងក៏ហៅឱ្យមកអង្គុយលេងជាមួយនាង។បន្ទាប់មកឈ្មោះ [redacted] ចាន់ វណ្ណៈពេជ្រ បានសុំនាងដាក់ម៉ូតូចូលក្នុងបន្ទប់ ហើយក៏បានប្រាស់ដេកលើគ្រែរបស់នាងធ្វើដេកលក់ ហើយនាងក៏បានដេកនៅខាងក្រោម លុះដល់ម៉ោង០១ និង៣០នាទីយប់ ឈ្មោះ [redacted] ចាន់វណ្ណៈពេជ្រ ធ្វើសកម្មភាពចាប់រំលោភសេពសន្ថវៈទៅលើឈ្មោះ [redacted] ងា ដោយបានគំរាមមិនឱ្យស្រែក រហូតបានសម្រេច ទើបជនជាប់ចោទដើរចេញពីបន្ទប់ ដោយបានបន្សល់ទុកម៉ូតូមួយគ្រឿង។

បានឃើញរបាយការណ៍សំយោគលេខ ២៤០/២០១៩ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់ការិយាល័យបទល្មើសជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៨៦៦ អ.យ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥២២៤ ពស.ព្រស "ឃ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ:១៣៦៥ ពស.ព្រជ (ក) ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២០ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

បានឃើញ ដីកាផ្តល់ដំណឹងកាលបរិច្ឆេទសវនាការ ដែលធ្វើឡើងដោយមានអនុលោមតាមមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## នាពេលសវនាការ

-តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ងា ថា:នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១០យប់ ខ្លួនបានអង្គុយលេងនៅមាត់បន្ទប់របស់ខ្លួន ហើយក៏ឃើញឈ្មោះ [redacted] ចាន់វណ្ណៈពេជ្រ ហៅ ពេជ្រ ដែលត្រូវជាមិត្តប្រុសរបស់មិត្តភ័ក្តិរបស់ខ្លួនដែលរស់នៅបន្ទប់ជួលជិតគ្នា ដែលមានទីតាំងនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ដោយខ្លួនឃើញឈ្មោះ ពេជ្រ អត់សោចូលបន្ទប់ ខ្លួនក៏ហៅឈ្មោះ ពេជ្រ មកអង្គុយលេងនៅមុខបន្ទប់ខ្លួនសិន ហើយឈ្មោះ ពេជ្រ ក៏បានមកអង្គុយលេងនៅមុខបន្ទប់របស់ខ្លួនមួយសន្ទុះក្រោយមកឈ្មោះ ពេជ្រ ក៏បានសុំខ្លួនដាក់ម៉ូតូក្នុងបន្ទប់ខ្លួនសិនហើយខ្លួនក៏យល់ព្រមឱ្យដាក់ព្រោះឈ្មោះ ពេជ្រ បាននិយាយថាដាក់ម៉ូតូខាងក្រៅខ្លាចចោរលួច ហើយខ្លួនយល់ព្រម ថាជាមនុស្សរាប់អានគ្នាបានខ្លួនឱ្យដាក់ម៉ូតូក្នុងបន្ទប់ រួចហើយឈ្មោះ ពេជ្រ ក៏ធ្វើជាដេកនៅលើពូករបស់ខ្លួន តែខ្លួនអង្គុយលេងទូរស័ព្ទធម្មតានៅខាងក្រោម ក្រោយមកទៀតឈ្មោះ ពេជ្រ បានឱ្យខ្លួនបិទទ្វារព្រោះខ្លាចចោរចូល ពេលនោះខ្លួនក៏បិទ ឈ្មោះ ពេជ្រ ក៏ត្រឡប់មកដេកលើពូកវិញក៏ដេកលក់ទៅ ចំណែកខ្លួននៅខាងក្រោមលក់ដែរ ដល់ម៉ោងប្រហែល១និង៣០នាទី រាត្រីឈ្មោះ ពេជ្រ បានធ្វើសកម្មភាពរំលោភខ្លួនតែម្តងដោយគេហាមមិនឱ្យខ្លួនស្រែក ខ្លួនក៏មិនហ៊ានស្រែក ។



Scanned with CamScanner

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ខេម** ថា:នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ មានបុរសម្នាក់ឈ្មោះ ពេជ្រ ដែលរស់នៅបន្ទប់ជួលជិតគ្នាបានរំលោភខ្លួនបានសម្រេចនៅក្នុងបន្ទប់របស់ខ្លួនដែលស្ថិតនៅក្នុងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ខ្លួនសុំទាមទារសំណងជម្ងឺចិត្តចំនួន២០០០(ពីរពាន់)ដុល្លារអាមេរិក។

-តាមអំណានឯកសារពិនិត្យ ការរំលោភផ្លូវភេទលេខ ៩២១/១៩ ម.ស.ខ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់គណកម្មការកោសលវិច័យខេត្តសៀមរាប សន្និដ្ឋានថា:តាមការពិនិត្យជាក់ស្តែងលើរូបរាងកាយនិងប្រដាប់ភេទរបស់ឈ្មោះ [redacted] ដា ភេទ ស្រី បញ្ជាក់ថា: សន្ទះព្រហ្មចារីមានស្នាមរហែកចាស់ចំណុចម៉ោង១២ មានផ្ទៃពោះពីរអាទិត្យ ហើយសរីរាង្គផ្សេងៗទៀតមានសភាពធម្មតា។

-តាមអំណានកំណត់ហេតុពិនិត្យកន្លែងកើតហេតុ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ របស់មន្ត្រីនគរបាលយុត្តិធម៌ថា:កន្លែងកើតហេតុស្ថិតនៅក្នុងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ថា:ទិសខាងត្បូងមានប្រវែង០,៥m ទៅទល់និងពូកដេក,ទិសខាងត្បូងឈាងខាងលិចមានប្រវែង៤mទៅទល់និងទ្វារបន្ទប់ ទិសខាងលិចមានប្រវែង២mទៅទល់និងទ្វារបន្ទប់ទឹក។ក្រៅពីនេះយើងពុំបានពិនិត្យអ្វីគួរអោយកត់សម្គាល់ទៀតទេ។

-តាមអំណានរបាយការណ៍សំយោគលេខ:២៤០ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ របស់ស្នងការនគរបាលខេត្តសៀមរាប សន្និដ្ឋានថា:ផ្អែកតាមពាក្យបណ្តឹងបងស្រីជនរងគ្រោះ ,ផ្អែកតាមការស្តាប់បំភ្លឺរបស់ជនរងគ្រោះ,ផ្អែកតាមលទ្ធផលកោសល្យវិច័យជនរងគ្រោះ ថា:ជនជាប់ចោទឈ្មោះ [redacted] ចាន់វណ្ណៈពេជ្រ ភេទប្រុស ពិតជាបានធ្វើសកម្មភាពរំលោភសេពសន្ថវៈ លើក្មេងស្រីឈ្មោះ [redacted] ដា អាយុ១៧ឆ្នាំ ពិតប្រាកដ អំពើនេះមានចែងក្នុងមាត្រា២៣៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីធ្វើការពិភាក្សា សួរដេញដោលរួចមកឃើញថា ឈ្មោះ [redacted] ចាន់វណ្ណៈពេជ្រ ត្រូវបានចោទប្រកាន់ពីបទ *រំលោភសេពសន្ថវៈ* ប្រព្រឹត្តនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ។ ដូច្នេះក្នុងនាមតំណាងអយ្យការ សុំតំកល់ការចោទប្រកាន់ ដូចក្នុងដីកាសន្និដ្ឋានស្ថាពរ និងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះដដែល និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទ តាមច្បាប់កំណត់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីធ្វើការពិភាក្សា និងស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការរួចមកឃើញថា កូនក្តីខ្លួនត្រូវចោទប្រកាន់ពីបទ *រំលោភសេពសន្ថវៈ*។ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ សុំតុលាការឲ្យកូនក្តីខ្លួនរួចផុតពីទោស តាមការចោទប្រកាន់ បញ្ញត្តិមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងការប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា



Scanned with CamScanner

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ពិតជាមានករណី **រំលោភសេពសន្ថវៈ** ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចាន់វណ្ណៈពេជ្រ នៅចំណុចភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ប្រាកដមែន។

២-ចម្លើយរបស់ជនរងគ្រោះនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ មានភាពស៊ីសង្វាក់គ្នាទៅនឹងលទ្ធផលកោសលវិច័យលេខៈ៩២១ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ គួរឲ្យជឿបានថាជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ដូចការបញ្ជូនមកជំនុំជម្រះប្រាកដមែន។

៣-សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការ រំលោភសេពសន្ថវៈទៅលើជនរងគ្រោះ ដែលច្បាប់បានបញ្ញត្តិថាជាបទល្មើស និងត្រូវផ្តន្ទាទោស ។

៤-ជនជាប់ចោទជានីតិជន ហើយពុំមានសញ្ញាណណាមួយ ដែលនាំឲ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយដូច្នេះ ជនជាប់ចោទត្រូវតែទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។

៥-អំពើរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម។

៦-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ការពិតពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ ។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ចាន់វណ្ណៈពេជ្រ ភេទប្រុស អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។

៨-ក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទបានរត់គេចខ្លួន គប្បីតុលាការចេញដីកាបង្គាប់ឲ្យចាប់ និងឃុំខ្លួនតាមមាត្រា៣៥៣ នៃនីតិវិធីព្រហ្មទណ្ឌ ។

៩-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខែម ទាមទារសំណងជម្ងឺចិត្តចំនួន២,០០០(ពីរពាន់)ដុល្លារអាមេរិក គប្បីតុលាការ និងសម្រេចតាមការភាពសមហេតុផល។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] **ចាន់វណ្ណៈពេជ្រ** ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **០៥(ប្រាំ)ឆ្នាំ**។

ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted] **ចាន់វណ្ណៈពេជ្រ** តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៣-ឲ្យឈ្មោះ [redacted] ចាន់ខណ្ណុះពេជ្រ សំណងជម្ងឺចិត្តចំនួន៤.០០០.០០០(បួនលាន)រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខេម ត្រូវបដិសេធចោលការទាមទារលើសពីនេះ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ ដោយកំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិអោយជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។

បើកសិទ្ធប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | |

[redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

សៀមរាប , ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]